**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

តុលាការកំពូល
សំណុំរឿង រដ្ឋប្បវេណី
លេខៈ ៣២២
ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ ២០០១
<u>សាលដីកា</u>
លេខៈ ២០៩
ចុះថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ ២០០៣

តាងនាមប្រជារាស្ត្រខ្មែរ
<u>តុលាការកំពូល</u>

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ២០០៣ ដោយមានសមាសភាពដូចតទៅៈ

១-ឯកឧត្តម ............ ជាប្រធានក្រុមប្រឹក្សាជំនុំជំរះ
២-លោក ............... ជាចៅក្រម
៣-លោក .................ជាចៅក្រម
៤-លោក ............... ជាចៅក្រម
៥-លោក ................ ជាចៅក្រមរបាយការណ៍

<u>ក្រឡាបញ្ជី</u>

-លោក .................

<u>តំណាងមហាអយ្យការ</u>

-លោក ............... ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាលេខ១០១(ឈ)ចុះថ្ងៃទី១២ខែកក្កដាឆ្នាំ ២០០១ នៃសំណុំរឿងរដ្ឋប្បវេណីលេខ១០៩ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ ២០០១ របស់សាលាឧទ្ធរណ៍ ។

រវាងដើមចោទឈ្មោះ គជ (ជាចុងបណ្តឹងសាទុក្ខ)ភេទប្រុស អាយុ៤៣ ឆ្នាំជាតិខ្មែរ មុខរបរលក់ដូរ ទីលំនៅសព្វថ្ងៃទីភូមិទី១ ឃុំវាលវង់ ស្រុកកំពង់ចាម ខេត្តកំពង់ចាម ។ឪពុកឈ្មោះ គង់ ថន (រ) ម្តាយឈ្មោះ តុង យ៉េក (ស) ប្រពន្ធឈ្មោះ កួយ ហ្គេកហ៊ាង មានកូន០៤ នាក់ ។

មានមេធាវីលោក .............. ។

ចុងចម្លើយឈ្មោះ ផឈរ (ម្ចាស់បណ្តឹងសាទុក្ខ) ភេទ ប្រុស អាយុ៣៩ ឆ្នាំ ជាត់ខ្មែរ ទីលំនៅសព្វថ្ងៃភូមិ១២ ឃុំកំពង់ចាម ស្រុកកំពង់ចាម ខេត្តកំពង់ចាម។ ឪពុកឈ្មោះ ជុក យ៉េន(ស) ម្តយ ឈ្មោះ ទឹម ស៊ីម (ស) ប្រពន្ធឈ្មោះ ហុង ផល្លា មានកូននាក់ ។

ផ្ទេរសិទ្ធិឲ្យឈ្មោះ យវជ ។

ចុងចម្លើយឈ្មោះ យវជ (ជាម្ចាស់បណ្តឹងសាទុក្ខអាយុក៤៩ ឆ្នាំ ជាតិខ្មែរ មុខរបរធ្វើពេទ្យ ទីលំនៅសព្វទី៦ ឃុំវាលវង់ ស្រុកកំពង់ចាម ខេត្តកំពង់ចាម ។ឪពុកឈ្មោះ យុន រិន(ស) ម្តាយឈ្មោះ ហេ ញ៉េ(រ) ប្រពន្ធឈ្មោះ ត្រេះ ហ៊ាន មានកូន៣នាក់ ។

**<u>កម្មវត្ថុបណ្តឹងៈ</u>** ប្តឹងទាមទារប្រាក់

បានឃើញបណ្តឹងសាទុក្ខលេខ ៣៣០ ចុះថ្ងៃទី២៧ ខែកញ្ញាឆ្នាំ២០០១ របស់ឈ្មោះ ឃវេធ និងថុក ឈាងវ៉ន ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ១០១ (ឈ) ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ៣២២ ចុះថ្ងៃទី ០៧ ខែវិច្ឆកា ឆ្នាំ២០០១ របស់តុលាការកំពូល។

តាមពាក្យបណ្តឹងរបស់ដើមចោទបញ្ជាក់ថា ចុងចម្លើយបានយកប្រាក់ពីខ្លួននិងយកដីព្រមទាំងពូជពោតសរុបជាប្រាក់ ១៤.១២២ ដុល្លាអាមេរិក ហើយសន្យាថា ប្រមូលផលពោតលក់ឲ្យខ្លួនវិញតែចុងចម្លើយមិលក់ឲ្យខ្លួនវិញគ្រប់ចំនួនឡើយ ហើយក៏មិនបានសងប្រាក់មកខ្លួនដែរ ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ២០៨ (ក) ចុះថ្ងៃទី ០៧ ខែវិច្ឆកា ឆ្នាំ២០០០ របស់តុលាការខេត្ត កំពង់ចាម ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅៈ

១-ទទួលពាក្យបណ្តឹងរបស់ដើមចោទចុះថ្ងៃទី ១៣ ខែកញ្ញា ឆ្នាំ២០០០ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ និងគតិច្បាប់ ។

២-ទទួលពាក្យបណ្តឹងសារត្រឡប់របស់ចុងចម្លើយ ចុះថ្ងៃទី១៨ ខែកញ្ញាឆ្នាំ២០០០ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

៣-ទទួលស្គាល់កិច្ចសន្យាលក់ទំនិញចុះថ្ងៃទី ១២ ខែមេសា ឆ្នាំ២០០០ រវាងភាគី(ក) តំណាងដោយលោក គជ និងភាគី (ខ) តំណាងដោយឈ្មោះ ថុក ឈាងវ៉ន និងឈ្មោះ ឃវេធ ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ (តាមមាត្រា ៣ នៃក្រិត្យច្បាប់លេខ ៣៨ ស្តីពីកិច្ចសន្យា)។

៤-ឲ្យចុងចម្លើយឈ្មោះ ថុក ឈាងវ៉ន និងឈ្មោះ ឃវេធ រួមគ្នាសងប្រាក់ចំនួន ១០.១៥៩ ដុល្លាអាមេរិក (មួយម៉ឺនមួយរយហាសិបប្រាំបួនដុល្លាអាមេរិក) និងការប្រាក់៥% ក្នុង១ឆ្នាំ គិតពីថ្ងៃទី ១២ ខែមេសា ឆ្នាំ២០០០ រហូតដល់ថ្ងៃសងប្រាក់គ្រប់ចំនួន ព្រមទាំងជំងឺចិត្តចំនួន ៦.០០០.០០០៛(ប្រាំមួយលានរៀល)ឲ្យទៅឈ្មោះ គជ ចាប់ពីពេលដែលសាលក្រមនេះ ចូលជាស្ថាពរ ។ ការទាមទារលើសពីនេះលើកចោល (តាមមាត្រា២២,៣១ និងមាត្រា ៥៩ នៃក្រិត្យច្បាប់លេខ ៣៨ ស្តីពីកិច្ចសន្យា)។

៥-នៅពេលដែលសាលក្រមនេះចូលជាស្ថាពរហើយ បើឈ្មោះ ថុក ឈាងវ៉ន និងឈ្មោះ ឃវេធ មិនព្រមអនុវត្តតាមចំណុចទី៤ នៃសាលក្រមនេះទេ តុលាការនឹងរឹបអូសទ្រព្យសម្បត្តិជាចលនវត្ថុនិងអចលនវត្ថុរបស់ឈ្មោះ ថុក ឈាងវ៉ន និងឈ្មោះ ឃវេធ លក់ឡាយឡុងដើម្បីសងប្រាក់ទៅឈ្មោះគជ ក្នុងករណីចុងចម្លើយទាំងពីនាក់មានឧបាយកលទុច្ចរិត តុលាការនឹងចាប់បង្ខំដល់រូបកាយឈ្មោះ ថុក ឈាងវ៉ន និងឈ្មោះ ឃវេធ ដាក់គុកកំណត់៨ខែ ។(តាមមាត្រា២៤ នៃក្រិត្យច្បាប់លេខ ៣៨ ស្តីពីកិច្ចសន្យា និងមាត្រា ១៣៣ នៃច្បាប់ស្តីពីនីតិវិធីអនុវត្តសាលក្រមរដ្ឋប្បវេណី)

៦-រឹបអូសប្រាក់ប្រដាប់ក្ដីចំនួន ១៤០០០៛ ដែលដើមចោទនិងចុងចម្លើយបានបង់ទុករួចហើយ ពេលសាលក្រមស្ដាពបង្គាប់ឲ្យចុងចម្លើយបង់សងទៅដើមចោទវិញ ចំនួន ៧០០០៛ និងឲ្យចុងចម្លើយបង់ពន្ធសមាមាត្រ១%លើប្រាក់១០.១៥៩ ដុល្លាអាមេរិក ស្មើនឹងប្រាក់ចំនួន ១៥៩ ដុល្លាអាមេរិក ។

៧-សាលក្រមនេះ ប្រកាសជាសាធារណៈចំពោះមុខដើមចោទ និងចំពោះមុខចុងចម្លើយទាំងពីរនាក់ សម្រេចបើកផ្លូវឧទ្ធរណ៍តាមច្បាប់កំណត់ ។

បានឃើញបណ្ដឹងឧទ្ធរណ៍លេខ ០៣ ចុះថ្ងៃទី៤ខែមករា ឆ្នាំ២០០១ របស់ឈ្មោះ ជុក ឈាងវ៉ន និងឈ្មោះ យវេធ ប្ដឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ ២០៨ (ក) ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០០០ របស់តុលាការខេត្តកំពង់ចាម ត្រង់ចំណុចនៃសាលក្រមទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ៣០ (ឈ) ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ៖

១-ទទួលពាក្យបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី០៤ ខែមករាឆ្នាំ២០០១ របស់ចុងចម្លើយទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២-តំកល់សាលក្រមលេខ ២០៨ (ក) ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០០០ របស់តុលាការខេត្តកំពង់ចាមទុកជាត្រឹមត្រូវពេញទាំងមូល ។

៣-រឹបអូសប្រាក់ប្រដាប់ក្ដីជាន់សាលាឧទ្ធរណ៍ចំនួន ១៣០០០៛ ដែលដើមបណ្ដឹងឧទ្ធរណ៍បានបង់រួចហើយ គឺពន្ធចុះបញ្ជីក្ដី និងពន្ធហ្នឹងចំនួន ២៥៥០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិប្រាក់ចំនួន ៤៥០៛ រង្វាន់អ្នកប្រគល់ដីកាកោះចំនួន ៥០០០៛ និងចំណាយលើអាជ្ញាធរតុលាការចំនួន ៥០០០៛

៤-សាលដីកានេះជំនុំជំរះនិងប្រកាសជាសាធារណៈចំពោះមុខដើមចោទកំបាំងមុខចុងចម្លើយ។ បើកផ្លូវប្ដឹងតវ៉ាតាមកំណត់ច្បាប់ ។

បានឃើញបណ្ដឹងទាស់លេខ ២៩ ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០០១ របស់ឈ្មោះ ជុក ឈាងវ៉ន និងឈ្មោះ យវេធ ប្ដឹងមិនសុខចត្តិនឹងសាលដីការដ្ឋប្បវេណីលេខ ៣០ (ឈ) ចុះថ្ងៃទី ១៥ ខែមីនា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចនៃសេចក្ដីសម្រេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ១០១ (ឈ) ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ៖

១-ទទួលពាក្យបណ្ដឹងទាស់ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០០១ របស់ចុងចម្លើយទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-បដិសេធសាលដីកាកំបាំងមុខរបស់សាលាឧទ្ធរណ៍លេខ ៣០ (ឈ) ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០១ ចោលជាអសារបង់ ។

៣-តំកល់សាលក្រមរដ្ឋប្បវេណីលេខ ២០៨ (ក) ចុះថ្ងៃទី ០៧ ខែវិច្ឆកា ឆ្នាំ២០០០ របស់តុលាការខេត្តកំពង់ចាមទុកជាបានការ លើកលែងតែចំណុចទី០៤ នៃសាលក្រមត្រូវបដិសេធ ។

៤-បង្គាប់ឲ្យឈ្មោះ ថុក ឈាងវ៉ន និងឈ្មោះ ឃវធ រួមគ្នាសងប្រាក់ចំនួន១២.២៨០$ (មួយម៉ឺនពីរពាន់ពីររយប៉ែតសិបដុល្លាអាមេរិក) និងការប្រាក់៥%ក្នុងមួយឆ្នាំគិតពីថ្ងៃទី១២ ខែមេសា ឆ្នាំ២០០០ រហូតសងប្រាក់គ្រប់ចំនួន និងជំងឺចិត្ត ៦.០០០.០០០៛ (ប្រាំមួយលានរៀល)ទៅឲ្យដើមចោទឈ្មោះ គជ ។

៥-បង្គាប់ឲ្យឈ្មោះ គជ សងប្រាក់ចំនួន ៦.៩១៩.៩៤០៛ (ប្រាំមួយលានប្រាំបួនសែនមួម៉ឺនប្រាំបួនពាន់ប្រាំបួនរយសែសិបរៀល)និងការប្រាក់៥%ក្នុង១ឆ្នាំ គិតពីថ្ងៃទី១២ ខែមេសា ឆ្នាំ២០០០ រហូតសងប្រាក់គ្រប់និងជំងឺចិត្ត ១.០០០.០០០៛ (មួយលានរៀល)ឲ្យទៅចុងចម្លើយឈ្មោះ ថុក ឈាងវ៉ន និងឈ្មោះ ឃវធ ។

៦-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន ១៣០០០៛ គឺពន្ធចុះបញ្ជីក្តី និងពន្ធហ្វឹង២៥៥០៛ រង្វាន់ក្រឡាបញ្ជីបញ្ជីកាន់ហិបប្រាក់៤៥០៛ រង្វាន់អ្នកប្រគល់ដិកាកោះ ៥០០០៛ និងចំណាយលើអាជ្ញាធរតុលាការ ៥០០០៛ និងបង្គាប់ឲ្យគូភាគីបង់ពន្ធសមាមាត្រ១% លើទឹកប្រាក់ទាំងអស់ដែលខ្លួនត្រូវសងទៅភាគីម្ខាងរៀងៗខ្លួន ។

៧-សាលដីកានេះ ជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខមេធាវីតំណាងដើមចោទកំបាំងមុខចុងចម្លើយ ទុកជាចំពោះមុខបើកផ្លូវសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ ៣៣០ ចុះថ្ងៃទី២៧ ខែកញ្ញាឆ្នាំ២០០១ របស់ឈ្មោះ ឃវធ និង ថុក ឈាងវ៉ន ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ១០១ (ឈ) ចុះថ្ងៃទី១២ខែកក្កដា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

បានឃើញសារណាការពារ ចុះថ្ងៃទី៣១ ខែធ្នូឆ្នាំ២០០១ របស់ឈ្មោះ ឃវធ និងថុក ឈាងវ៉ន។

បានឃើញសារណាតប ចុះថ្ងៃទី០៤ ខែមេសាឆ្នាំ២០០២ របស់ឈ្មោះ គជ ។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថាៈ សូមក្រុមប្រឹក្សាជំនុំជំរះ ពិនិត្យនិងសម្រេចតាមច្បាប់ ។

បានស្តាប់ចម្លើយរបស់ឈ្មោះ ឃវធ នាពេលសវនាការថាៈ បានជាខ្លួនប្តឹងសាទុក្ខពីសាលដីការបស់សាលាឧទ្ធរណ៍ មកពីមានចំណុចដូចខាងក្រោមនេះ ៖

-សុំបដិសេធការបូកសរុបរបស់ខេត្តចំនួន ៥.១០០.០០០៛

-សុំឲ្យគង់ជរ ប្រគល់ឲ្យខ្លួន ២.៥៤០.០០០៛ ដែលគាត់ឲ្យប្រជាជនខ្ចី

-ការរកស៊ី គជ មិនទូទាត់សោះ គឺប្តឹងតែម្តង

-សុំឲ្យ គជ ងាកបែរក្រោយទៅរកកិច្ចសន្យាលក់ ទិញគ្រាប់ពោតដែល គជ លក់ឲ្យប្រជាជនផង លក់ឲ្យខ្លួនផង ។

-គជ ក្បត់កិច្ចសន្យា ចំហុយពោតឡើងខ្លោច មិនយកតាមកំដៅថ្ងៃទេ ។

-សូមឯកឧត្តម ឲ្យគជគោរពនូវកិច្ចសន្យាតាមប្រការ២ និងប្រការ៣ អំពីភាពរាំងស្ងួត

-សុំឲ្យគជ សងថ្លៃពោតខ្លួន ១៩.០០០.០០០៛

-សុំឲ្យគជ កាត់ពូជឲ្យគេ

-សុំឲ្យគង់ជរ យកប្រាក់លំអៀងឲ្យខ្លួនដោយសងមួយគីឡូក្រាម ២០៛

-សុំឲ្យគជ ទៅជួយទារលុយជាមួយខ្លួន ពីប្រជាជនដែលបានជំពាក់

-ដីចំនួន៥០បេ សុំយកមកវិញ

-ថ្លៃឡូ គឺគាត់ឲ្យប្រជាជនខ្ចីក្នុងលុយ៥.០០០.០០០៛

-លុយមិនទាន់បានទូទាត់ទេ គឺមកឲ្យតុលាការទូទាត់ឲ្យ

-សូមឲ្យតុលាការជួយរកយុត្តិធម៌ឲ្យត្រឹមត្រូវតាមវិក័យបត្រ ។

បានស្តាប់ចម្លើយរបស់លោក គជ នាពេលសវនាការថាៈ ខ្លួនសុំបដិសេធទាំងស្រុង គឺខ្លួនគ្មានសិទ្ធិទៅទារលុយពីប្រជាជនទេ ។ នៅមានកិច្ចសន្យាក្រោយៗទៀតជាច្រើន តែខ្លួនមិនប្តឹងទេ គឺប្តឹងតែកិច្ចសន្យាមុនមួយទេ ។ខ្លួនទទួលវិក័យបត្រ ៣ដងហើយ សរុប ១៤៥តោន ។កម្រៃជើងសារមួយគីឡូក្រាម ២០៛ទូទាត់រួចហើយ ហើយថ្លៃឡូ បានទូទាត់ភ្លាមៗ ។ ប្រាក់ថ្លៃភ្ជួរដី បើកពីខ្លួនយកទៅភ្ជួរចាំបានផលទើបទូទាត់គ្នា

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោក ............... ជាមេធាវីការពារឲ្យដើមចោទ នាពេលសវនាការថាៈ រឿងក្តីនេះ ថុក ឈាងវ៉ែន និងឃវធ គ្មានឯកសារជូនសំអាងទេ នៅតុលាការថ្នាក់ក្រោម ។នៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០១ ពេលសាលាឧទ្ធរណ៍ហៅគាត់ គាត់មិនចូលទេ រួចគាត់ក៏ប្តឹងទាស់ ដល់កាត់លើកទី២ នៅតែមិនចូល ។គាត់បានទទួលស្គាល់វិក័យបត្របង្វិលដី និងគ្រាប់ពូជគឺស៊ីសងគ្នាក្រៅរួចអស់ហើយ ។ការរកស៊ីនេះមាន៣ដំណាក់កាល ខ្លួនពិបាកស្វែងយល់ណាស់ ព្រោះឃវធទើបតែជូនសំអាងថ្មីទៀត ។

សូមតុលាការរក្សាសាលដីការបស់សាលាឧទ្ធរណ៍ទុកជាបានការ ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយរបស់គូភាគី និងសេចក្តីសន្និដ្ឋានការពាររបស់មេធាវីដើមចោទ

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៣៣០ ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០១ របស់ឈ្មោះឃរធ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះ មកជំនុំជំរះបានតាមមាត្រា ១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

-យល់ឃើញថាការដែលសាលាឧទ្ធរណ៍សម្រេចសេចក្តីដោយអាងហេតុថា ចុងចម្លើយបានទទួលប្រាក់ពីដើមចោទចំនួន ៤២.៤៧២.៥៤០៛ និង១២.២៨០ ដុល្លាអាមេរិក ហើយដើមចោទ បានទទួលគ្រាប់ពោតពីចុងចម្លើយចំនួន ៥៦.៤៨៥ គក + ៥០.០២៦ គក + ៣៨.៧៦១ គក នោះពុំទាន់មានសំអាង ហេតុគ្រប់គ្រាន់ទេ ពីព្រោះថាៈ

ក/វិក័យបត្រទទួលទិញគ្រាប់ពោត ដែលដើមចោទទទួលពីចុងចម្លើយមាន ៣ ប៉ុន្តែតាមប័ណ្ណប្រគល់ទំនិញ គឺបានទូទាត់ តែលើប័ណ្ណ ទទួលទិញគ្រាប់ពោតតែពីប៉ុណ្ណោះ ។

ខ/តាមប័ណ្ណប្រគល់ដែលចុងចម្លើយ បានប្រគល់ឲ្យដើមចោទមានៈ

-ប័ណ្ណចុះថ្ងៃទី ២២ ខែសីហា ឆ្នាំ២០០០ មានទឹកប្រាក់៨៩៤.៩២០ ៛

-ប័ណ្ណចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០០០ មានពូជពោតចំនួន ២៨B តម្លៃ១៥៦៨ ដុល្លាអាមេរិក និងជីគីមី៥B តម្លៃ៦៥ដុល្លាអាមេរិក

-ប័ណ្ណចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០០០ មានពូជពោតចំនួន ២២B តម្លៃ១២៣២ ដុល្លាអាមេរិក ជីគីមី ៥B តម្លៃ៦៥ ដុល្លាអាមេរិក និងទឹកប្រាក់ចំនួន ១៥៤០.០០០៛

ដូច្នេះតុលាការពុំមានភស្តុតាងស្តីពីការទូទាត់ប្រាក់ទាំងនេះ ដើម្បីសម្រេចឲ្យគូភាគីសងគ្នាទៅវិញទៅមកទេ ។

យល់ឃើញថា តុលាការបានសម្រេចឲ្យគូភាគីបង់ការប្រាក់៥% ក្នុង១ឆ្នាំគិតពីថ្ងៃទី១២ ខែមេសា ឆ្នាំ២០០០ គឺគិតពីថ្ងៃទីចុះកិច្ចសន្យា ។ប៉ុន្តែក្នុងកិច្ចសន្យានេះ ពុំបានចែងពីការប្រាក់ទេ ។

-យល់ឃើញថា ចុងចម្លើយបានលើកឡើងថា ដើមចោទពុំបានគោរពតាមប្រការ២ និងប្រការ៣ នៃកិច្ចសន្យាទេ ប៉ុន្តែសាលាឧទ្ធរណ៍ក៏ពុំទាន់បានពិចារណាក្នុងការយល់ឃើញរបស់ខ្លួនលើបញ្ហានេះដែរ។

-យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ ១០១ (ឈ) ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ដែលបាន សម្រេចសេចក្តីមកនេះមានការខុសឆ្គងទាំងទម្រង់ និងគតិច្បាប់ ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តី ចំពោះមុខគូក្តី

១-ទទួលបណ្តឹងសាទុក្ខលេខ ៣៣០ ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០១ របស់ឈ្មោះ ឃរធ ជាត្រឹមត្រូវទាំងទម្រង់ ទាំងគតិច្បាប់

២-ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ ១០១ (ឈ) ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣-បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ ៣២២ ចុះថ្ងៃទី០៧ ខែវិច្ឆកា ឆ្នាំ២០០១ របស់តុលាការកំពូលទៅសាលាឧទ្ធរណ៍ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤-រឹបអូសប្រាក់ប្រដាប់ក្តីដែលឈ្មោះ ឃវេធ បានបង់ទុកនៅតុលាការកំពូលចំនួន ១៩០០០៛គឺ

-ពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹងចំនួន ៤០០០៛ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០៛ សម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់

-ចំណាយក្នុងកិច្ចប្រគល់ដីកាកោះចំនួន ១៥០០០៛ សរុប ១៩០០០៛ ហើយតម្រូវឲ្យដើមចោទសងប្រាក់ចំនួន ១៩០០០៛ នេះទៅចុងចម្លើយវិញ ។

៥-សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០០៣ ។